**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៩៣២ អ.ក

ចុះថ្ងៃទី១៨-វិច្ឆិកា-២០២០

សាលក្រមលេខៈ ៣៣ (ន)

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៩៣២ អ.ក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ÷ ឈ្មោះ [redacted] ធីម ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរជាងដែក ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហាន (រស់) ម្ដាយឈ្មោះ [redacted] យ៉ន (រស់) ប្រពន្ធឈ្មោះ [redacted] លក្ខិណា (រស់) គ្មានកូន ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារខេត្តកំពង់ស្ពឺចំនួន០២ឆ្នាំ ពីបទៈ ជួញដូរគ្រឿងញៀន។ **(ឃុំខ្លួនថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០)**

-ជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៧** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោក [redacted] ការិយាល័យមេធាវី សហស្សវត្ស ទីតាំងស្ថិតនៅផ្ទះលេខ ១១២-១១៤ ផ្លូវលេខ១១៣០ សង្កាត់ផ្សារកណ្ដាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីម។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧៧៤ ដកសព ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១៨៧៥ ដកដស ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៤១៨ ដកចផ/២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។



Scanned with CamScanner

## អង្គហេតុមានដូចតទៅ

-នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៧ និង៣០នាទី ស្ថិតនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កម្លាំងសមត្ថកិច្ចនគរបាល បានធ្វើការបង្ក្រាបករណីគ្រឿងញៀន ដោយឃាត់ខ្លួនជនត្រូវចោទម្នាក់ឈ្មោះ [redacted] ធីម ភេទប្រុស អាយុ៣៨ឆ្នាំ ដែលបានយកថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) មានទម្ងន់សរុប ១១៦២,០២ក្រាម ដែលបានទិញពីឈ្មោះ វុន យកទៅលក់វិញក្នុងតម្លៃ ៩០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិច បន្ទាប់មកក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

## ពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ធីម បានឆ្លើយបញ្ជាក់ថាៈ សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំបាទ នៅវេលាម៉ោង១៧ និង៣០នាទី នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ដោយមានមនុស្សស្រីម្នាក់មិនស្គាល់ឈ្មោះ បានទូរស័ព្ទមកទិញថ្នាំញៀនពីខ្លួនចំនួន០១គីឡូក្រាម ក្នុងតម្លៃ៩០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិច។ ក្រោយមកខ្លួនបានកម្មង់ទិញពីឈ្មោះ វុន តាមរយៈទូរស័ព្ទPRIVATE ហើយឈ្មោះ វុន បានប្រើកូនចៅគាត់ចំនួន ០២នាក់ មិនស្គាល់ឈ្មោះ ជាអ្នកកាន់ថ្នាំញៀនមកជួបខ្លួនឲ្យដើរពីក្រោយខ្លួន យកទៅឲ្យគេអ្នកកម្មង់ទិញនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល នៅពេលទៅដល់ចំណុចនោះ មិនទាន់បានប្រគល់ឲ្យអ្នកទិញផង សមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនតែម្ដង។

-ក្រឡាបញ្ជីអានឯកសារនានានៅក្នុងសំណុំរឿងនេះ។

## សំអាងនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

**-តំណាងអយ្យការបានសន្និដ្ឋានថាៈ** សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៧៧៤ ដកសព ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ទុកជាការបានដដែល និងសុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

**-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ** [redacted] **ធីម បានសន្និដ្ឋានថាៈ** ស្នើសុំឲ្យតុលាការជួយសម្រាលទោសឲ្យកូនក្ដីខ្លួនផង ព្រោះជនជាប់ចោទបានឆ្លើយសារភាពនូវទោសកំហុសរបស់ខ្លួន។

## ផ្អែកតាមលទ្ធផលនៃការពិភាក្សាដេញដោល

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ធីម។

-ក្រោយពីបានស្ដាប់ការអានឯកសារនានា។

-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ធីម។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

## តុលាការយល់ឃើញថា

១- កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៧ និង៣០នាទី មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ធីម ដែលប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល ពិតប្រាកដមែន។

២- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ធីម បានឆ្លើយបញ្ជាក់ថាៈ សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំបាទ នៅវេលាម៉ោង១៧ និង៣០នាទី នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ នៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ដោយមានមនុស្សស្រីម្នាក់មិនស្គាល់ឈ្មោះ បានទូរស័ព្ទមកទិញថ្នាំញៀនពីខ្លួនចំនួន០១គីឡូក្រាម ក្នុងតម្លៃ៩០០០

Scanned with CamScanner

(ប្រាំបួនពាន់) ដុល្លារអាមេរិច។ ក្រោយមកខ្លួនបានកម្មង់ទិញពីឈ្មោះ រុន តាមរយៈទូរស័ព្ទ PRIVATE ហើយឈ្មោះ រុន បានប្រើក្មួនចៅគាត់ចំនួន ០២នាក់ មិនស្គាល់ឈ្មោះ ជាអ្នកកាន់ថ្នាំញៀនមកជួបខ្លួនឱ្យដើរពីក្រោយខ្លួន យកទៅឱ្យគេអ្នកកម្មង់ទិញនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល នៅពេលទៅដល់ចំណុចនោះមិនទាន់បានប្រគល់ឱ្យអ្នកទិញផង សមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនតែម្តង។ ខ្លួនទិញពីឈ្មោះ រុន ក្នុងតម្លៃ ៩០០០ (ប្រាំបួនពាន់) ដុល្លារអាមេរិច លក់ឱ្យគេវិញក្នុងតម្លៃ ៩៥០០(ប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិច។ ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ រុន បួនទៅប្រាំដង ទិញក្នុងមួយលើកតម្លៃជាង ១.០០០.០០០ (មួយលាន)រៀល លក់ឱ្យគេតាមទូរស័ព្ទចំណេញម្តងៗជាង ២០.០០០០ (ម្ភៃម៉ឺន)រៀល ដោយធ្វើសកម្មភាពលក់ជាង០៣ខែមកហើយ។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់ ទៅនឹងចម្លើយជនជាប់ចោទ នៅគ្រប់ដំណាក់កាលនីតិវិធី មានលក្ខណៈស៊ីចង្វាក់ទៅនឹងឯកសារនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថាៈ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១៧ និង៣០នាទី ជនជាប់ចោទឈ្មោះ [redacted] ធីម បានធ្វើសកម្មភាពយកថ្នាំញៀន ០១កញ្ចប់ធំ ដែលមានទម្ងន់ ១១៦២,០២ក្រាម (មួយពាន់មួយរយហុកសិបពីរក្បៀសសូន្យពីរក្រាម) យកទៅលក់ឱ្យស្រីម្នាក់នៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ស្ថិតនៅភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ហើយត្រូវសមត្ថកិច្ចឃាត់ខ្លួនជាក់ស្តែងតែម្តង។

៣- តាមកំណត់ហេតុចាប់យកវត្ថុ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ រួមមានៈ ម្សៅក្រាមពណ៌សថ្លា (មេតំហ្វេតាមីន) ទម្ងន់ ១១៦២,០២ក្រាម និងទូរស័ព្ទដៃចំនួន ០១គ្រឿង ដែលសមត្ថកិច្ចដកហូតពីជនជាប់ចោទឈ្មោះ ម៉ៅ ធីម។

៤- តាមកំណត់ហេតុ ធ្វើតេស្តទឹកនោម និងវត្ថុតាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ជាលទ្ធផលដែលបានមកពីការប្រតិកម្មរបស់ឧបករណ៍ពិសោធន៍ទឹកនោម បង្ហាញជាលទ្ធផល÷ វិជ្ជមាន(+)។

៥- តាមកំណត់ហេតុបើកកញ្ចប់វត្ថុតាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានបើកកញ្ចប់វត្ថុតាងឃើញមានម្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀន ចំនួន០១កញ្ចប់ធំ ច្រកក្នុងថង់ប្លាស្ទិក ពណ៌សថ្លា។

៦- តាមកំណត់ហេតុ ធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដែលបានដកហូតសារធាតុញៀនខុសច្បាប់ មានទម្ងន់ ១១៦២,០២ក្រាម (មួយពាន់មួយរយហុកសិបពីរក្បៀសសូន្យពីរក្រាម) បានធ្វើតេស្តដោយឧបករណ៍ពិសោធន៍រកសារធាតុញៀន Marquis Test បានបង្ហាញជាលទ្ធផលមានវត្តមានសារធាតុ **មេតំហ្វេតាមីន** ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់សារធាតុត្រូវហាមឃាត់ក្នុងតារាង ២ នៃឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២។

៧- តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខៈ ៣៣៨៣៧/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាលទ្ធផល វិជ្ជមាន វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ការសន្និដ្ឋាន÷ សំណាកគ្រឿងញៀនជាប្រភេទក្រាមម្សៅថ្លាឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៥,៦៧%។

៨- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ធីម មានចេតនាទុច្ចរិតធ្វើសកម្មភាពលក់ថ្នាំញៀន ដើម្បីបានប្រាក់ចំណេញ ដោយថ្នាំញៀនមានទម្ងន់សរុប ១១៦២,០២ក្រាម x ៧៥,៦៧ ÷ ១០០= ៨៧៩,៣០ (ប្រាំបីរយ na

ចិតសិបប្រាំបួនក្បៀសសាបសិបក្រាម) គឺជាបទល្មើសព្រហ្មទណ្ឌបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌទី៣ និងកថាខណ្ឌទី៧** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៩- តំណាងអយ្យការបានប្ដឹងសុំឱ្យតុលាការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ **១៧៧៤** ដកសព ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ ទុកជាការបានដដែល និងសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវ តុលាការនឹងពិចារណាចំពោះការប្ដឹងសុំនេះ។

១០- សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ [redacted] ធីមៈ បានស្នើសុំឱ្យតុលាការជួយសម្រាលទោសឱ្យកូនក្ដីខ្លួនផង ព្រោះជនជាប់ចោទបានឆ្លើយសារភាពនូវទោសកំហុសរបស់ខ្លួន។ តុលាការពិចារណាឃើញថាមិនមានលក្ខខណ្ឌណាមួយ ដែលអាចឱ្យតុលាការសម្រេចតាមការស្នើសុំបានទេ។

១១- ជនជាប់ចោទឈ្មោះ [redacted] ធីម ជានីតិជន មានស្មារតី និងសមត្ថភាព យល់ដឹងគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់នូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

១២- ក្រោយពីបានពិនិត្យ ពិចារណាលើភស្តុតាង និងរាល់សេចក្ដីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើ÷ ឈ្មោះ [redacted] ធីម ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌទី៣ និងកថាខណ្ឌទី៧** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣- ជនជាប់ចោទឈ្មោះ [redacted] ធីម គឺបានធ្វើសកម្មភាពជួញដូរថ្នាំញៀនយ៉ាងសកម្ម និងជាច្រើនលើកច្រើនសារដើម្បីបានប្រាក់ចំណេញ ហើយជាក់ស្ដែងថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានមានទម្ងន់រហូតដល់ **១១៦២,០២** (មួយពាន់មួយរយហុកសិបពីរក្បៀសសូន្យពីរក្រាម) មានបរិមាណសុទ្ធទម្ងន់ ៨៧៩,៣០ (ប្រាំបីរយចិតសិបប្រាំបួនក្បៀសសាបសិបក្រាម)។ ដូច្នេះគប្បីតុលាការពិចារណាដាក់ទណ្ឌកម្មឱ្យបានធ្ងន់តាមអំពើប្រព្រឹត្តរបស់ជនជាប់ចោទ តាមមាត្រា ៤០ **កថាខណ្ឌទី៣ និងកថាខណ្ឌទី៧** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ធីម បានធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកដទៃ សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយរបស់សង្គម និងច្បាប់របស់រដ្ឋ។

១៥- វត្ថុតាង÷ ម្សៅក្រាមពណ៌សថ្លា (មេតំហ្វេតាមីន) ទម្ងន់ ១១៦២,០២ក្រាម (មួយពាន់មួយរយហុកសិបពីរក្បៀសសូន្យពីរក្រាម) មានបរិមាណសុទ្ធទម្ងន់ ៨៧៩,៣០ (ប្រាំបីរយចិតសិបប្រាំបួនក្បៀសសាបសិបក្រាម) និងទូរស័ព្ទដៃចំនួន០១គ្រឿងម៉ាក NOKIA អិលចុចពិល (ចាស់មិនដំណើរការ) ពណ៌ខៀវលាយខ្មៅ គប្បីតុលាការសម្រេចរឹបអូស និងបំផ្លាញចោល តាមមាត្រា **៨៤** និង មាត្រា **៩៣** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>សេចក្ដីសម្រេច</u>

១- ផ្ដន្ទាទោស÷ ឈ្មោះ [redacted] ធីម ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ **ដាក់ពន្ធនាគារកំណត់ ២៥(ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០,០០០,០០០ (សែសិបលាន) រៀល។**

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខក្លោងទ្វារវត្តដំណាក់អំពិល ភូមិលាប់ពស់ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ **កថាខណ្ឌទី៣ និងកថាខណ្ឌទី៧** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

Scanned with CamScanner

២- វត្ថុតាង÷ ម្សៅក្រាមពណ៌សថ្លា (មេតំហ្វេតាមីន) ទម្ងន់ ១១៦២,០២ក្រាម (មួយពាន់មួយរយហុកសិបពីរក្បៀសសូន្យពីរក្រាម) មានបរិមាណសុទ្ធទម្ងន់ ៨៧៩,៣០ (ប្រាំបីរយចិតសិបប្រាំបួនក្បៀសសាបសិបក្រាម) និងទូរស័ព្ទដៃចំនួន០១គ្រឿងម៉ាក NOKIA អិលចុចពិល (ចាស់មិនដំណើរការ) ពណ៌ខៀវលាយខ្មៅ សម្រេចរឹបអូស និងបំផ្លាញចោល តាមមាត្រា ៨៤ និង មាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធីម។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |

[redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្តាល, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

កណ្តាល, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner